**Embassy of Japan in Cambodia**

# Press Release

No. 18 PR-26/EoJ 1 May 2026

## Application opened for “NODOJIMAN” Japanese Song Contest 2026

The Embassy of Japan is pleased to announce that the Embassy, in cooperation with the Cambodia-Japan Cooperation Center (CJCC) and the Japan Foundation, Phnom Penh Liaison Office, is going to hold “NODOJIMAN” Japanese Song Contest 2026 on Sunday, 12 July 2026 at the CJCC during the Tanabata Festival 2026.

The “NODOJIMAN” Japanese Song Contest has been held for the purpose of encouraging Japanese language learners to practice vocalization of the language. This contest also aims to enhance friendship and mutual understanding between the people of Japan and Cambodia through Japanese songs.

All Cambodians who would like to sing a Japanese song in Japanese are invited to apply for the contest via Microsoft Forms (https://forms.office.com/r/4pLq1Ccfjm). The application deadline is 31 May 2026.

For further information, please contact the Culture and Information Section of the Embassy of Japan at 023 217 161 (1122) or email to info.jpn@pp.mofa.go.jp .

# Guidelines for “NODOJIMAN” Japanese Song Contest 2026

## Program of the Contest

**Date:** **Application Opens**: 1 May (Fri) (online applications only)

**Application Deadline**: 31 May (Sun)

**Announcement Preliminary Results**: 19 June (Fri)

**Final Round**: 12 July (Sun) 15:00-17:30 (tentative)

* The Final round will be held at CJCC as part of the Tanabata Festival (Star Festival), scheduled for 10-12 July 2026.

**Venue**: Angkor-Kizuna Hall, CJCC

**Eligibility:** All Cambodians who enjoy singing Japanese songs in Japanese are welcome to apply. Applicants can participate either solo or as a group.

## Application for the Preliminary Round

- Applicants must fill in all columns in the Microsoft Forms application: (https://forms.office.com/r/4pLq1Ccfjm) by **31 May 2026 (Sun)**.
- Results of the Preliminary round will be announced on **19 June (Fri)** on the Embassy of Japan’s website and Facebook page.

## Entry of Final Round

- Karaoke track must be submitted to the Embassy by **26 June 2026 (Fri)**.
- No karaoke machine will be available at the venue. Participants need to memorize their own lyric sheets.
- Participants are requested to arrive at the Angkor-Kizuna Hall by **1:30 pm on 12 July 2026 (Sun)** for rehearsal.

  Rehearsal Time: 1:30pm – 2:30pm

  Contest Time : 3:00pm – 5:30pm

  * Please note that the above schedule is subject to change.

## Contact Information

- For inquiries, please contact the Culture and Information Section of the Embassy of Japan in Cambodia.

  Phone Number: 023 217 161 (ext.1122)

  Email Address: info.jpn@pp.mofa.go.jp

## ស្ថានទូតជប៉ុនប្រចាំកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

លេខ៖ 18 PR-26/EoJ                                        ថ្ងៃទី១ ខែឧសភា ឆ្នាំ២០២៦

## ការចាប់ផ្តើមទទួលពាក្យសុំចូលរួម
## ការប្រឡងចម្រៀងណូដូជីម៉ាន់២០២៦

ស្ថានទូតជប៉ុនមានសេចក្តីសោមនស្សរីករាយសូមជម្រាបជូនថា ស្ថានទូត រួមសហការជាមួយមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-ជប៉ុន(CJCC) ការិយាល័យទំនាក់ទំនងភ្នំពេញនៃមូលនិធិជប៉ុន នឹងរៀបចំនូវការប្រឡងចម្រៀងណូដូជីម៉ាន់២០២៦ (ការប្រឡងចម្រៀងភាសាជប៉ុន) នៅថ្ងៃអាទិត្យ ទី១២ ខែកក្កដា ឆ្នាំ២០២៦ នៅCJCC ក្នុងឱកាសពិធីបុណ្យផ្កាយ (តាណាបាតា) ២០២៦ ផងដែរ។

ការប្រឡងចម្រៀងណូដូជីម៉ាន់(ចម្រៀងភាសាជប៉ុន) ត្រូវបានប្រារព្ធឡើងក្នុងគោលបំណងលើកទឹកចិត្តអ្នកសិក្សាភាសាជប៉ុនបានអនុវត្តការបញ្ចេញសំឡេងជាភាសាជប៉ុន។ លើសពីនេះទៀត ការប្រឡងនេះក៏មានគោលបំណងពង្រឹងចំណងមិត្តភាព និងការយល់ដឹងអំពីគ្នាទៅវិញទៅមករវាងប្រជាជនជប៉ុន និងកម្ពុជា តាមរយៈចម្រៀងភាសាជប៉ុនផងដែរ។

យើងខ្ញុំ សូមស្វាគមន៍ប្រជាជនកម្ពុជាគ្រប់រូបដែលចូលចិត្តច្រៀងចម្រៀងភាសាជប៉ុន ចូលរួមប្រឡងចម្រៀងនេះ តាមរយៈ Microsoft Form ដែលមានភ្ជាប់ (https://forms.office.com/r/4pLq1Ccfjm)។ ការដាក់ពាក្យនឹងផុតកំណត់ត្រឹមថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៦។

សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទងមកកាន់ផ្នែកវប្បធម៌ និងព័ត៌មាននៃស្ថានទូតជប៉ុន តាមរយៈទូរស័ព្ទលេខ ០២៣ ២១៧ ១៦១ (១១២២) ឬផ្ញើអ៊ីម៉េលមកកាន់អាស័យដ្ឋាន៖ info.jpn@pp.mofa.go.jp ។

---

*Embassy of Japan in Cambodia*
*Tel: 023 217 161, Email: info.jpn@pp.mofa.go.jp,*
*Official Website: www.kh.emb-japan.go.jp*

# សេចក្តីណែនាំនៃការដាក់ពាក្យប្រឡងចម្រៀងណូដូជីម៉ាន់២០២៦

កម្មវិធីប្រឡងចម្រៀងណូដូជីម៉ាន់

**កាលបរិច្ឆេទ៖**

**បើកទទួលពាក្យ៖** ថ្ងៃសុក្រ ទី១ ខែឧសភា តាមអនឡាញ

**បិទទទួលពាក្យ៖** ថ្ងៃអាទិត្យ ទី៣១ ខែឧសភា

**ប្រកាសលទ្ធផលវគ្គជម្រុះ៖** ថ្ងៃសុក្រ ទី១៩ ខែមិថុនា

**វគ្គផ្តាច់ព្រ័ត្រ៖** ថ្ងៃអាទិត្យ ទី១២ ខែកក្កដា ឆ្នាំ២០២៦ ម៉ោង ១៥:០០-១៧:៣០(អាចកែប្រែ)

*ការប្រឡងវគ្គផ្តាច់ព្រ័ត្រ នឹងរៀបចំឡើងនៅCJCC ក្នុងឱកាសពិធីបុណ្យតាណាបាតា (ពិធីបុណ្យផ្កាយ) ដែលនឹងប្រព្រឹត្តិទៅចាប់ពីថ្ងៃទី១០ ដល់ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២៦។

**ទីកន្លែង៖** នៅសាលអង្គរ-គីហ្សូណា CJCC

**លក្ខខណ្ឌក្នុងការជ្រើសរើស៖** ស្វាគមន៍បេក្ខជនដែលមានសញ្ជាតិខ្មែរចូលរួមប្រឡងចម្រៀងណូដូជីម៉ាន់២០២៦។ បេក្ខជនអាចប្រឡងចម្រៀងទោល ឬ ប្រឡងជាក្រុម។

ការដាក់ពាក្យសម្រាប់វគ្គជម្រុះ

- បេក្ខជនត្រូវបំពេញគ្រប់ចំនុចដែលតម្រូវក្នុង Microsoft Form (https://forms.office.com/r/4pLq1Ccfjm) (ពេលដាក់ពាក្យ ត្រូវតែភ្ជាប់លីងវីដេអូចម្រៀងរបស់ខ្លួន) ឱ្យបានត្រឹមថ្ងៃអាទិត្យ ទី៣១ ខែឧសភា។
- លទ្ធផលបេក្ខជនជាប់វគ្គជម្រុះ ដើម្បីចូលរួមការប្រឡងចម្រៀងណូដូជីម៉ាន់២០២៦ វគ្គផ្តាច់ព្រ័ត្រ នឹងត្រូវប្រកាសនៅថ្ងៃសុក្រ ទី១៩ ខែមិថុនា នៅលើគេហទំព័រ និងហ្វេសប៊ុកស្ថានទូតជប៉ុន។

ដំណើរការនៃវគ្គផ្តាច់ព្រ័ត្រ

- បេក្ខជនដែលចូលរួមប្រឡងវគ្គផ្តាច់ព្រ័ត្រ ត្រូវត្រៀមភ្លេងសម្រាប់ច្រៀងនៅថ្ងៃប្រឡងដោយខ្លួនឯង ហើយត្រូវផ្ញើមកកាន់ស្ថានទូតជាមុន ត្រឹមថ្ងៃសុក្រ ទី២៦ ខែមិថុនា។
- ការប្រឡងចម្រៀងនេះ មិនមានម៉ាស៊ីនខារ៉ាអូខេដែលអាចមើលឃើញអក្សរចម្រៀងទេ ដូច្នេះបេក្ខជនត្រូវទន្ទេញចាំបទចម្រៀង ឬត្រៀមណោតទំនុកច្រៀងដោយខ្លួនឯង។
- បេក្ខជនចូលរួមប្រឡងវគ្គផ្តាច់ព្រ័ត្រ តម្រូវមកកាន់ទីតាំងដើម្បីសម នៅសាលអង្គរ-គីហ្សូណា នៅម៉ោង១៣:៣០ នៅថ្ងៃអាទិត្យ ទី១២ ខែកក្កដា ឆ្នាំ២០២៦។

  ពេលវេលាសម៖ ១៣:៣០- ១៤:៣០

  ពេលវេលាប្រឡងចម្រៀង៖ ១៥:០០ -១៧:៣០

  * បញ្ជាក់ពេលវេលាខាងលើអាចកែប្រែ។

ព័ត៌មានលម្អិត

- សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទងមកកាន់ផ្នែកវប្បធម៌ និងព័ត៌មាននៃស្ថានទូតជប៉ុន
- ទូរសព្ទលេខ ០២៣ ២១៧ ១៦១ (លេខភ្ជាប់បន្ត១១២២)
- អាសយដ្ឋានអ៊ីម៉ែល៖ info.jpn@pp.mofa.go.jp